# ផតខាសស៊េរី វិទ្យាស្ថាន CDRI វគ្គទី១ (CDRI Podcast Series episode 1)៖
# "ក្រឡេកមើលឆ្នាំ២០២០ និងសម្លឹងឆ្ពោះទៅឆ្នាំ២០២១៖ ផ្នត់គំនិតនៃវិស័យឯកជន"

**អំពីផតខាសស៊េរី វិទ្យាស្ថាន (CDRI Podcast Series) ៖**

សូមស្វាគមន៍មកកាន់ផតខាសស៊េរី វិទ្យាស្ថាន (CDRI Podcast Series)។ ផតខាសនេះ គឺជាផ្នែកមួយនៃគម្រោងស្រាវជ្រាវថ្នាក់តំបន់រវាងបណ្តាប្រទេសក្នុងមហាអនុតំបន់មេគង្គ ដោយមានជំនួយឧបត្ថម្ភមូលនិធិពីមជ្ឈមណ្ឌលស្រាវជ្រាវដើម្បីការអភិវឌ្ឍអន្តរជាតិនៃប្រទេសកាណាដា។

ផតខាសនេះ ផ្តោតលើ៖ ១) ការចែករំលែកចំណេះដឹង និងលទ្ធផលទទួលបានពីការស្រាវជ្រាវដែលទាក់ទងនឹងផលប៉ះពាល់ជំងឺកូវីដ១៩ ទៅលើសុខុមាលភាពសេដ្ឋកិច្ចសង្គមរបស់ក្រុមជនងាយរងគ្រោះ ស្ត្រី និងសហគ្រាសធុនតូច និងមធ្យម និង ២) ការចូលរួមជាមួយភាគីពាក់ព័ន្ធក្នុងការពិភាក្សាដែលផ្តល់ចំណេះដឹងនានាទាក់ទងនឹងជំងឺកូវីដ១៩ និងផលប៉ះពាល់របស់វា។

**អំពីផតខាសស៊េរី វិទ្យាស្ថាន វគ្គទី១(CDRI Podcast Series episode 1) ៖**

លោកស្រី ស្រ៊ី បុប្ផារ័ត្ន គឺជាអ្នកសម្របសម្រួលក្នុងផតខាសស៊េរី វិទ្យាស្ថាន CDRI វគ្គទី១ ក្រោមប្រធានបទ "ក្រឡេកមើលឆ្នាំ២០២០ និងសម្លឹងឆ្ពោះទៅឆ្នាំ២០២១៖ ផ្នត់គំនិតនៃវិស័យឯកជន"។ ជំងឺកូវីដ១៩ ផ្តល់ផលប៉ះពាល់យ៉ាងច្រើនទៅលើផ្នែកសេដ្ឋកិច្ចសង្គម ហើយជំងឺនេះកំពុងប៉ះពាល់លើដំណើរការអាជីវកម្ម និងប្រាក់ចំណូល។ ជំងឺកូវីដ១៩ ក៏ផ្តល់ប៉ះពាល់អវិជ្ជមានដល់វិស័យផ្សេងទៀតរួមមាន៖ វិស័យកសិកម្ម កម្មន្តសាល ទេសចរណ៍ និងបដិសណ្ឋារកិច្ច។ រយៈពេលមួយឆ្នាំ ចាប់តាំងពីការផ្ទុះឡើងនៃជំងឺកូវីដ១៩ មានភាពមិនប្រាកដប្រជាជាច្រើន លាយនឹងការវាយតម្លៃថា តើជំងឺរាតត្បាតសកលនេះ រួមទាំងផលប៉ះពាល់របស់វា នឹងត្រូវបញ្ចប់ទៅវិញនៅពេលណា។

ឧកញ៉ា សុខ ពិសិដ្ឋ ជាវាគ្មិនកិត្តិយសដែលចូលរួម ផតខាស របស់យើងថ្ងៃនេះ។ ឧកញ៉ា ពិសិដ្ឋ មានបទពិសោធន៍ជាច្រើនឆ្នាំក្នុងការគ្រប់គ្រងអាជីវកម្ម និងគាំទ្រដល់ប្រព័ន្ធសហគ្រិនចម្រុះនៅកម្ពុជា។ ឧកញ៉ា ពិសិដ្ឋ សកម្មក្នុងការដេដែកផ្នែកគោលនយោបាយជាមួយរាជរដ្ឋាភិបាលកម្ពុជា និងភាគីពាក់ព័ន្ធផ្សេងទៀត។ ឧកញ៉ា ពិសិដ្ឋ ជានាយកប្រតិបត្តិ និងសហស្ថាបនិក G GEAR Group។ ឧកញ៉ា ពិសិដ្ឋ ក៏ជាសមាជិកក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ដែរ។

**សំណួរទៅកាន់វាគ្មិន និងចម្លើយ៖**

**ផ្នែក ‘ក’៖ ‘ក្រឡេកមើលឆ្នាំ២០២០’**

សំណួរទី១

*(នាទី ០២៖១៥)*

**បុច្ឆាវ័ន្ត៖** តើលោកឧកញ៉ាអាចសង្ខេបពីផលប៉ះពាល់នៃជំងឺកូវីដ១៩ ទៅលើអាជីវកម្មឯកជនក្នុងប្រទេសកម្ពុជាបានដែរឬទេ ចាប់តាំងពីការផ្ទុះឡើងនៃជំងឺរាតត្បាតសកលនេះ?

*(នាទី ០២៖២៤)*

**ឧកញ៉ា សុខ ពិសិដ្ឋ៖** ជំងឺកូវីដ១៩ ផ្តល់ផលប៉ះពាល់មិនត្រឹមតែនៅប្រទេសកម្ពុជាទេ តែជុំវិញពិភពលោកតែម្តង។ ផលប៉ះពាល់ទាំងនោះ បានជំរុញឱ្យសេដ្ឋកិច្ចពិភពលោក និងប្រទេសនានាជួបវិបត្តិ។ ជារឿងដ៏ល្អមួយ ដែលរាជរដ្ឋាភិបាលកម្ពុជា ទប់ទល់នឹងការរីករាលដាលនៃជំងឺកូវីដ១៩ បានល្អ។ មានករណីឆ្លងម្តងម្កាលដែរ តែរដ្ឋាភិបាលទប់ទល់បាន ដោយសារមានគោលការណ៍ចត្តាឡីស័កបានខ្ជាប់ខ្ជួន។

- សម្រាប់ប្រទេសកម្ពុជា ខ្ញុំមើលឃើញផលប៉ះពាល់ផ្ទាល់នៃជំងឺកូវីដ១៩ ដែលមានសភាពធ្ងន់ធ្ងរ ទៅលើវិស័យទេសចរណ៍ ដូចជា ផ្នែកបដិសណ្ឋារកិច្ច រួមមាន សណ្ឋាគារ ភោជនីយដ្ឋាន ជាពិសេសនោះ គឺខេត្តដែលទទួលបានប្រាក់ចំណូលពីវិស័យវិស័យទេសចរណ៍ ដូចជា ខេត្តសៀមរាប។ នៅពេលអាជីវកម្មមួយទទួលរងផលប៉ះពាល់ វានឹងមានផលប៉ះពាល់បន្តគ្នាដូច ដូមីណូ អញ្ចឹង (domino effect)។ វាជាបញ្ហាប្រឈមមួយ។
- ដោយសារតែមានផលប៉ះពាល់ជាសកលលោក ប្រទេសមួយចំនួន បានឈប់ទិញផលិតផលពីប្រទេសយើង។ វិស័យកម្មន្តសាល និងវាយនភ័ណ្ឌ ក៏ទទួលរងផលប៉ះពាល់ខ្លាំងដែរ ទាក់ទងនឹងការនាំចេញទៅសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប។

ជារួមមក ផលប៉ះពាល់ទាំងអស់នេះ នាំឱ្យកំណើនសេដ្ឋកិច្ចថមថយ។ ហេតុដូចនេះហើយទើបផលិតផលក្នុងស្រុកសរុប (ផសស) របស់យើង ធ្លាក់ចុះដល់ចំណុចអវិជ្ជមាន (GDP minus) ក្នុងឆ្នាំ២០២០ ដែលមិនធ្លាប់បានជួបប្រទះទេក្នុង ២ទសវត្សរ៍ចុងក្រោយនេះ។

សំណួរទី២

*(នាទី ០៤៖២២)*

**បុច្ឆាវ័ន្ត៖**

(១) តើផលប៉ះពាល់មានភាពខុសគ្នាយ៉ាងដូចម្តេចដែរ រវាងសហគ្រាសធុនតូច និងមធ្យម និងក្រុមហ៊ុនធំ?

(២) តើផលប៉ះពាល់នេះទៀតសោត មានភាពខុសគ្នាយ៉ាងដូចម្តេចដែរ រវាងសហគ្រាសដឹកនាំដោយបុរស និងសហគ្រាសដឹកនាំដោយស្ត្រី?

*(នាទី ០៤៖៤៩)*

**ឧកញ៉ា សុខ ពិសិដ្ឋ៖**

(១) ខ្ញុំគិតថា ផលប៉ះពាល់មិនមានភាពខុសគ្នាច្រើនទេ រវាងសហគ្រាសធុនតូច និងមធ្យម និងក្រុមហ៊ុនធំ។

- កត្តាកំណត់ភាពខុសគ្នាខ្លាំង ឬតិចនៃផលប៉ះពាល់ ស្ថិតនៅលើទុនបម្រុង និងការរៀបចំផែនការអាជីវកម្ម។ ឧទាហរណ៍ នៅក្រុមហ៊ុន G GEAR Group កំឡុងឆ្នាំ២០១៩ យើងបានធ្វើផែនការថវិកាសម្រាប់ឆ្នាំ២០២០ ទុកមុន។
  - យើងបានទាយទុកមុនថា វិបត្តិសេដ្ឋកិច្ចអាចនឹងកើតមានឡើងក្នុងឆ្នាំ២០២០។ ជាសំណាងល្អដែរ ដែលយើងអាចមើលឃើញថា វិបត្តិសេដ្ឋកិច្ចអាចនឹងកើត មុនពេលដែលមានការរាតត្បាតរបស់ជំងឺកូវីដ១៩។ ដូច្នេះហើយ យើងបានត្រៀមថវិកាបម្រុងរួចជាស្រេច ដើម្បីទប់ទល់វិបត្តិដែលយើងបានទាយទុក។
  - តាមពិតទៅ ក្រុមហ៊ុនយើងក៏ទទួលរងផលប៉ះពាល់ដែរ តែមិនមានផលប៉ះពាល់ធ្ងន់ធ្ងរទេ ដោយសារតែអាជីវកម្មយើង ទាក់ទងនឹងការលក់ឧបករណ៍គ្រឿងអេឡិចត្រូនិច។ អាជីវកម្មប្រភេទនេះ មិនមានផលប៉ះពាល់ផ្ទាល់ទេ។ កាលពីឆ្នាំមុន យើងលក់ផលិតផលអេឡិចត្រូនិចដាច់គួរសម ជាពិសេសក្នុងកំឡុងពេលរាតត្បាតនៃជំងឺកូវីដ១៩ តែម្តង។ អតិថិជនសម្រុកទិញទូរទឹកកក ដើម្បីរក្សាទុកម្ហូបអាហារឱ្យបានយូរ។

សរុបមក ភាពខុសគ្នារវាងសហគ្រាសធុនតូច និងមធ្យម និងក្រុមហ៊ុនធំ គឺទុនបម្រុង និងការរៀបចំផែនការអាជីវកម្ម។ សម្រាប់សហគ្រាសធុនតូច និងមធ្យម ខ្ញុំគិតថា សមត្ថភាពពួកគេនៅមានកម្រិតក្នុងការប្រមើលមើល ឬទាយទុកមុនពីស្ថានភាព ឬវិបត្តិសេដ្ឋកិច្ចនាពេលអនាគត។ ការគ្រប់គ្រងអាជីវកម្មមានភាពដូចគ្នានឹងការគ្រប់គ្រងគ្រួសារដែរ។ យើងត្រូវមានទុនបម្រុង និងការទាយទុកជាមុន។ សម្រាប់ការទាយទុកមុនដែលមានវិជ្ជាជីវៈ និងតាមលក្ខខណ្ឌបច្ចេកទេស ត្រូវពឹងផ្អែកលើទិន្នន័យ។ ទិន្នន័យទាំងនោះប្រាប់ពីអ្វីដែលនឹងកើតឡើង។

(២) សម្រាប់ភាពខុសគ្នារវាងសហគ្រាសដែលដឹកនាំដោយបុរស និងសហគ្រាសដែលដឹកនាំដោយស្ត្រី ខ្ញុំមិនមានទិន្នន័យមកបញ្ជាក់ទេអំពីចំណុចនេះ។ សម្រាប់ខ្ញុំ បុរស និងស្ត្រី មានលក្ខណៈសម្បត្តិដែលជាចំណុចល្អ និងមិនសូវល្អរៀងៗខ្លួន។ សម្រាប់ខ្ញុំដែលជាបុរស ខ្ញុំគិតថា បុរសមានភាពដាច់ស្រេចក្នុងការសម្រេចចិត្ត។ សម្រាប់ស្ត្រី ខ្ញុំគិតថា ពួកគេមានភាពល្អិតល្អន់ខ្លាំងណាស់។ ដូច្នេះ ខ្ញុំពិបាកនិយាយណាស់ថា បុរស ឬស្ត្រី មានភាពដឹកនាំល្អជាង ព្រោះទាំងបុរស និងស្ត្រី មានចំណុចខ្លាំង និងចំណុចខ្សោយរៀងខ្លួន។

## សំណួរទី៣

*(នាទី ០៨៖៥៣)*

**បុប្ផារ័ត្ន៖** ខ្ញុំយល់ស្របនឹងអ្វីដែលលោកឧកញ៉ាបានលើឡើងទាក់ទងនឹងការរៀបផែនការទុកជាមុន។ ក្រុមហ៊ុនរបស់លោកធំគួរសម ទើបមានសមត្ថភាពក្នុងការត្រៀមទុនបម្រុង ដើម្បីទប់ទល់នឹងវិបត្តិនេះ។ នាងខ្ញុំសូមចូលទៅកាន់សំណួរបន្ទាប់ទៀត។ តើមានវិធានការអ្វីខ្លះដែលបានដាក់ចេញដោយក្រុមហ៊ុនរបស់លោកឧកញ៉ា ក្នុងការឆ្លើយតបនឹងជំងឺកូវីដ១៩ រាប់ចាប់តាំងពីការផ្ទុះឡើងនៃជំងឺរាតត្បាតសកលនេះ?

*(នាទី ០៩៖៣២)*

**ឧកញ៉ា សុខ ពិសិដ្ឋ៖** ដើម្បីឆ្លើយតបនឹងវិបត្តិមួយនេះ ក្រុមហ៊ុនរបស់យើងបានឆ្លើយតបភ្លាមៗទៅនឹងជំងឺកូវីដ១៩ សម្រាប់ផ្ទៃក្នុងក្រុមហ៊ុនយើងតែម្តង។

- ទី១៖ ក្នុងសេចក្ដីណែនាំប្រមាណ ១០ទំព័ររបស់ក្រុមហ៊ុនយើង ក្រុមឆ្លើយតបនឹងហានិភ័យ ត្រូវបានបង្កើតឡើងដែលមានសមាជិកចំនួន ១០នាក់ ពីផ្នែកផ្សេងៗរបស់ក្រុមហ៊ុន។ យើងបានបញ្ចូលព័ត៌មានជាច្រើនទៅក្នុងសេចក្ដីណែនាំរួមទាំង រោគសញ្ញា និងអាការៈនៃជំងឺកូវីដ១៩។ ប្រសិនបើមានអ្នកឆ្លងជំងឺកូវីដ១៩ យើងមានបន្ទប់បម្រុងសម្រាប់ពួកគាត់រួចជាស្រេច។
- ទី២៖ យើងមានគម្រោង និងគោលការណ៍បញ្ចូលប្រព័ន្ធឌីជីថលក្នុងការលក់ និងប្រតិបត្តិការអាជីវកម្ម។ ក្នុងឆ្នាំ២០១៩ យើងបានរៀបចំប្រព័ន្ធទាំងអស់នេះ។ ក្នុងពេលដែលមានការរាតត្បាតជំងឺកូវីដ១៩ ប្រព័ន្ធប្រតិបត្តិការអាជីវកម្មឌីជីថល ត្រូវបានដាក់ឱ្យប្រើប្រាស់ ដូច្នេះហើយការអនុម័តការងារមានភាពងាយស្រួលជាងមុន។ ទោះជាយើងមិនធ្វើការផ្ទាល់ពីការិយាល័យ ការងារមួយចំនួនអាចទទួលបានការអនុម័តទៅបាន។
- ទី៣៖ ការទូទាត់សាច់ប្រាក់តាម ABA ក៏មានភាពងាយស្រួលដែរ សម្រាប់ដំណើរការអាជីវកម្មរបស់យើង។ ការទូទាត់សាច់ប្រាក់នេះផងដែរ កាត់បន្ថយវិក័យបត្រច្រើនមែនទែន។ ពេលដែលពួកគាត់រៀបចំការទូទាត់សាច់ប្រាក់រួចរាល់ ខ្ញុំយល់ព្រម ហើយសាច់ប្រាក់នឹងត្រូវបានវេរភ្លាមៗតែម្ដង។
- ទី៤៖ យើងក៏បានដាក់លក់ផលិតផលលើបណ្ដាញសង្គម ហ្វេសប៊ុក (facebook) ផងដែរ។ យើងជម្រុញឱ្យមានការលក់តាមបែបឌីជីថល ដើម្បីរកប្រាក់ចំណេញដែលអាចជួយទប់នឹងទុនបម្រុងដែលយើងមាន។
- ទី៥៖ យើងក៏ផ្ដោតសំខាន់ទៅលើខេត្តដែលមិនសូវទទួលផលប៉ះពាល់ខ្លាំងពីជំងឺកូវីដ១៩។ យើងបានបើកហាងលក់រាយមួយចំនួនក្នុងខេត្តទាំងនោះ។ ដូច្នេះ យើងអាចធ្វើប្រមូសិន (promotion) ក្នុងការលក់ផលិតផល។
- ទី៦៖ ការធ្វើឱ្យបុគ្គលិកធ្វើការដោយមានទំនុកចិត្ត ក៏ជាផ្នែកមួយដ៏សំខាន់ដែរ។ យើងមានសេចក្ដីណែនាំ និងគោលការណ៍ប្រចាំក្រុមហ៊ុន ដូច្នេះហើយបុគ្គលិកមានទំនុកចិត្ត និងប្រឹងប្រែងធ្វើការបន្ថែម។ ខ្ញុំពិតជាអរគុណ ក្រុមការងារជួរមុខរបស់ខ្ញុំណាស់ដែលពួកគាត់ពុះពារ ខិតខំធ្វើការ ដើម្បីឱ្យក្រុមហ៊ុនយើងអាចបន្តទៅមុខក្នុងស្ថានការណ៍នេះ។

## សំណួរទី៤

*(នាទី ១៤៖០៩)*

**បុប្ផារ័ត្ន៖** លោកឧកញ៉ាបានរៀបរាប់អំពីការលក់ទំនិញតាមប្រព័ន្ធឌីជីថល ដែលទាក់ទងនឹងពាណិជ្ជកម្មអេឡិចត្រូនិច (e-commerce)។ ខ្ញុំគ្រាន់តែចង់ដឹងបន្តិចបន្តួចទៅលើទិន្នន័យលក់។ តើអតិថិជនគាំទ្រការលក់បែបថ្មីនេះជាង ឬក៏ពួកគាត់ចូលចិត្តការលក់ដោយផ្ទាល់?

*(នាទី ១៤៖៣៦)*

**ឧកញ៉ា សុខ ពិសិដ្ឋ៖** ខ្ញុំគិតថា វាអាស្រ័យនឹងជំនាន់ ឬក៏អាយុរបស់អតិថិជន។ អតិថិជនជំនាន់ថ្មី មានការយល់ដឹងក្នុងការប្រើបណ្ដាញទំនាក់ទំនងសង្គម ហើយពួកគេគាំទ្រពាណិជ្ជកម្មអេឡិចត្រូនិច (e-commerce)។ សូម្បីផ្នែកម្ហូបអាហារ ក៏មានលក្ខណៈអញ្ចឹងដែរ។ ចំណែកអតិថិជនជំនាន់ចាស់ ពួកគាត់មិនសូវស្គាល់ និងដឹងពីពាណិជ្ជកម្មអេឡិចត្រូនិច (e-commerce) ទេ។ យើងនៅចំណុចបំបែកមួយ។ ច្បាប់ស្ដីពីពាណិជ្ជកម្មអេឡិចត្រូនិច (e-commerce law) ទើបតែត្រូវមានអនុម័តទេ បើគិតមកទល់ពេលនេះ។

សរុបមក ពាណិជ្ជកម្មអេឡិចត្រូនិច (e-commerce) មានការលូតលាស់គួរឱ្យកត់សម្គាល់ក្នុងវិបត្តិជំងឺរាតត្បាតសកលនេះ។ ការលូតលាស់នៃពាណិជ្ជកម្មអេឡិចត្រូនិច (e-commerce) ក៏ពឹងផ្អែកទៅលើវិស័យនីមួយៗដែរ។ សម្រាប់វិស័យអាជីវកម្ម ផលិតផលអេឡិចត្រូនិច ដោយសារតែអតិថិជនចង់មើល ចង់ឃើញ ចង់ប៉ះ ខ្ញុំគិតថា ៨០% នៃអតិថិជន នៅតែចង់មកមើលផលិតផលអេឡិចត្រូនិចនៅហាងផ្ទាល់តែម្តង។ សម្រាប់វិស័យលក់សម្លៀកបំពាក់ និងស្បែកជើង ពាណិជ្ជកម្មអេឡិចត្រូនិច (e-commerce) ក៏កើតមានឡើងដែរ ហើយមានការទិញមកពីក្រៅប្រទេស។ ការទិញក្នុងកម្ពុជា ក៏មានដែរ។ ពួកគេក៏លក់តាមហ្វេសប៊ុកដែរ។

## សំណួរទី៥

*(នាទី ១៦៖៤០)*

**បុប្ផារ័ត្ន៖** លោកឧកញ៉ាបានរៀបរាប់ពីភាពផ្លាស់ប្តូរក្នុងក្រុមហ៊ុន និងបែបបទនៃការលក់ផងដែរ។ ទាក់ទងនឹងការគ្រប់គ្រង តើមានបញ្ហាប្រឈមអ្វីផ្សេងទេនៅពេលដែលលោកឧកញ៉ា បញ្ជ្រាបប្រព័ន្ធធ្វើការថ្មីឱ្យបុគ្គលិកក្រុមហ៊ុន?

*(នាទី ១៧៖០០)*

**ឧកញ៉ា សុខ ពិសិដ្ឋ៖** ការផ្លាស់ប្តូរមិនមានភាពងាយស្រួលទេ។ បុគ្គលិកគ្រប់គ្នា ត្រូវតែយល់ដឹងពីស្ថានភាពរបស់ក្រុមហ៊ុន។ សម្រាប់ក្រុមហ៊ុន G GEAR ការផ្លាស់ប្តូរខ្លះទាក់ទងនឹងការគ្រប់គ្រង ទាំងនោះមិនមែនជាបញ្ហាប្រឈមខ្លាំងប៉ុន្មានទេ។ បុគ្គលិកក្រុមការងារទាំងអស់ ស្ថិតនៅចំណុចមួយរួមគ្នា តាំងពីពួកយើងធ្វើយុទ្ធសាស្ត្រការងារសម្រាប់ឆ្នាំ២០២០ មកម្ល៉េះ។ ឥឡូវនេះ យើងគ្រោងដល់យុទ្ធសាស្ត្រការងារសម្រាប់ឆ្នាំ២០៣០ ហើយ។ សម្រាប់ពួកយើង យើងជួបបញ្ហាប្រឈមដែរ តែវាមិនដល់ថ្នាក់ធ្វើឱ្យយើងអស់កម្លាំងចិត្តក្នុងបំពេញការងារនោះទេ។ ពេលខ្លះការផ្លាស់ប្តូរអាចនឹងមានភាពជោគជ័យ ពេលខ្លះអាចធ្វើឱ្យមានបញ្ហាប្រឈមបន្ថែម ឬវិបត្តិតែម្តង។ ខ្ញុំអាចនិយាយបានថា មានវិស័យជាច្រើន បានរីកលូតលាស់ក្នុងកំឡុងពេលវិបត្តិជំងឺកូវីដ១៩ ជាពិសេសនោះ គឺការរីកចម្រើនផ្នែកឌីជីថល។

សរុបមកយើងមិនជួបប្រទះបញ្ហាប្រឈមអ្វីខ្លាំងពេកទេ។ យើងធ្វើការងារមួយជំហានម្តងៗ។ យើងយល់ដឹងពីកាលៈទេសៈ។

## សំណួរទី៦

*(នាទី ១៨៖៤៧)*

**បុប្ផារ័ត្ន៖** តើវិធានការគោលនយោបាយរបស់រដ្ឋាភិបាល បានជួយកាត់បន្ថយផលប៉ះពាល់នៃជំងឺកូវីដ១៩ ទៅលើអាជីវកម្មកម្រិតណាដែរ?

*(នាទី ១៩៖០៦)*

**ឧកញ៉ា សុខ ពិសិដ្ឋ៖** ក្នុងដើមឆ្នាំ២០២០ ខ្ញុំចាំបានថា យើង (វិស័យឯកជន) មានជំនួបជាមួយរាជរដ្ឋាភិបាល ដើម្បីពិភាក្សាថា តើវិស័យមួយណាត្រូវការការគាំទ្រ។ កាលនោះ យើងផ្តោតទៅលើខេត្តសៀមរាប G GEAR មិនមែនត្រឹមតែជាក្រុមហ៊ុនដែលធ្វើអាជីវកម្មដើម្បីតែចំណូលទេ។ ឆ្នាំមុន ក្នុងឆ្នាំ២០១៩ យើងបានផ្តល់ថវិកា ដល់អ្នកពិគ្រោះ

យោបល់ក្នុងការធ្វើការស្ទង់មតិអំពីទំនុកចិត្តអតិថិជនក្នុងខេត្តសៀមរាប ដោយសារតែយើងមើលឃើញថា វិស័យទេសចរណ៍នៅខេត្តសៀមរាបមានភាពថមថយ មិនមែនដោយសារតែផលប៉ះពាល់ជំងឺកូវីដ១៩ តែម្យ៉ាងទេ ប៉ុន្តែមានភាពថមថយប៉ុន្មានឆ្នាំ មុនការរាតត្បាតជំងឺកូវីដ១៩។ ពេលដែលយើងធ្វើការវិភាគ យើងឃើញថា អតិថិជន (value added customers) មានភាពថយចុះច្រើនខ្លាំង។ យើងចាប់ផ្តើមការស្ទង់មតិនៅខែតុលា ព្រោះយើងត្រូវការទិន្នន័យច្បាស់លាស់ ដើម្បីជម្រាបរដ្ឋាភិបាលអំពីការថមថយនៃវិស័យទេសចរណ៍នេះ។ ក្នុងដើមឆ្នាំ២០២០ យើងបញ្ជូនការស្រាវជ្រាវរបស់យើង ជូនទៅរាជរដ្ឋាភិបាល ក៏ដូចជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយសមាគមសហគ្រិនវ័យក្មេងកម្ពុជាប្រចាំខេត្តសៀមរាប ក៏បានធ្វើបទបង្ហាញទៅរដ្ឋាភិបាលថ្នាក់ខេត្ត។ ខ្ញុំគិតថា ការគាំទ្ររបស់រាជរដ្ឋាភិបាលក្នុងជុំទី១ ទី២ និងទី៣ ត្រូវបានធ្វើឡើង ដោយពឹងលើផ្នែកមួយចំនួនដែរ ទៅលើធាតុចូលដែលបានពីការស្ទង់មតិដែលខ្ញុំបានរៀបរាប់ខាងលើ។ តិច ឬច្រើន ខ្ញុំគិតថា រាជរដ្ឋាភិបាលរបស់យើងបំពេញការងារបានល្អ និងមានវិជ្ជាជីវៈមែនទែន ក្នុងការគាំទ្រក្នុងកំឡុងពេលការរាតត្បាតសកលនេះ។ គោលនយោបាយសារពើពន្ធ ជួយបានច្រើន តែយើងមិនមានគោលនយោបាយរូបិយវត្ថុ ជួយដល់សហគ្រាសធុនតូច និងមធ្យម ដោយសារយើងមានដុល្លារូបនីយកម្ម។ គោលនយោបាយសារពើពន្ធ បន្តជួយដល់ជុំទី៧ ហើយ។ តាំងពីខ្ញុំធ្វើការ និងប្រឡូកក្នុងវិជ្ជាជីវៈមកនេះជាលើកទី១ ហើយដែលខ្ញុំឃើញរាជរដ្ឋាភិបាល ធ្វើបានល្អយ៉ាងនេះ ក្នុងការទប់ទល់នឹងវិបត្តិ និងជួយស្តារសេដ្ឋកិច្ច។

## សំណួរទី៧

*(នាទី ២២៖៤១)*

**បុប្ផារ័ត្ន ៖** តើមេរៀនសំខាន់អ្វីខ្លះដែលលោកឧកញ៉ាគិតថា ម្ចាស់ ឬអ្នកគ្រប់គ្រងអាជីវកម្ម ជាពិសេសសហគ្រាសធុនតូច និងមធ្យម ទទួលបានពីវិបត្តិដែលបណ្តាលមកពីជំងឺរាតត្បាតសកលនេះទាក់ទងនឹងដំណើរការអាជីវកម្ម?

*(នាទី ២៣៖០៣)*

**ឧកញ៉ា សុខ ពិសិដ្ឋ ៖** ខ្ញុំគិតថាអ្វីដែលយើងអាចរៀនសូត្របានពីវិបត្តិជំងឺកូវីដ១៩ គឺ៖

- ទី១៖ ការសន្សំ និងការរៀបចំផែនការ។ ការធ្វើអាជីវកម្ម មិនអាចធ្វើមួយថ្ងៃគិតមួយថ្ងៃបានទេ។ យើងត្រូវតែរៀបចំផែនការ ដោយមើលទៅលើផលប៉ះពាល់ទាំងខាងក្នុង និងខាងក្រៅ។ ការងារជាក្រុម ក៏សំខាន់ណាស់ដែរ។ អាជីវកម្មមួយដែលមានភាពរលូន និងជោគជ័យ មិនមែនកើតមកដោយសំណាងទេ ប៉ុន្តែដោយសារមានការសាមគ្គីរបស់ក្រុម និងរចនាសម្ព័ន្ធ ដែលត្រូវបានបង្កើតឡើងជាយូរមកហើយ។
- ទី២៖ មេរៀនដែលសំខាន់មួយទៀតគឺ ក្រមសីលធម៌វិជ្ជាជីវៈ។ ក្រុមហ៊ុនដែលមានក្រមសីលធម៌វិជ្ជាជីវៈ នឹងមិនកាត់បន្ថយបុគ្គលិកទេ។ ក្រុមហ៊ុនដែលមានក្រមសីលធម៌វិជ្ជាជីវៈ នឹងខិតខំពុះពារឧបសគ្គទាំងអស់គ្នា ទោះជាមានការកាត់ប្រាក់ខែខ្លះក៏ដោយក្តី។ ក្រុមហ៊ុនខ្លះ ទោះជាពួកគាត់មិនទទួលផលប៉ះពាល់ផ្ទាល់ក្តី គាត់យកលេសខ្លះ ដើម្បីកាត់បន្ថយបុគ្គលិក។ ដូច្នេះ ពេលដែលយើងស្វែងរកការងារវិជ្ជាជីវៈ យើងគួរតែស្វែងយល់ពីក្រុមហ៊ុនផងដែរ។ មនុស្សភាគច្រើនមានទំនោរទៅលើក្រុមហ៊ុនបរទេស។ ពេលមានវិបត្តិដូចនេះ ក្រុមហ៊ុនបរទេសខ្លះ មិនសូវខ្វល់ខ្វាយទេ។ ពួកគេបិទក្រុមហ៊ុន ត្រឡប់ទៅស្រុកវិញ ឬក៏កាត់បន្ថយបុគ្គលិក។

ពេលមានវិបត្តិ គឺជាពេលមួយដែលអាចឱ្យយើងដឹងថា តើអាជីវកម្មណាត្រូវបន្ត ឬត្រូវបិទ ហើយអ្នកណាមាន ឬគ្មានក្រមសីលធម៌វិជ្ជាជីវៈ។

## ផ្នែក ‘ខ’៖ ‘សម្លឹងឆ្ពោះទៅឆ្នាំ២០២១’

### សំណួរទី៨

*(នាទី ២៥៖៤៤)*

**បុប្ផារ័ត្ន៖** សម្លឹងឆ្ពោះទៅឆ្នាំ២០២១ តើលោកឧកញ៉ា វាយតម្លៃស្ថានការណ៍យ៉ាងដូចម្តេច? បើនិយាយឱ្យចំ តើលោកឧកញ៉ាមានសុទិដ្ឋិនិយម ឬទុទិដ្ឋិនិយម ឬក៏មានអារម្មណ៍ធម្មតា ចំពោះស្ថានការណ៍ខាងមុខ? ហេតុអ្វី?

*(នាទី ២៦៖១៥)*

**ឧកញ៉ា សុខ ពិសិដ្ឋ៖** ខ្ញុំនៅតែមានសុទិដ្ឋិនិយម ចំពោះអាជីវកម្មរបស់ខ្ញុំ។ ក្នុងវិស័យរបស់ខ្ញុំ ខ្ញុំនៅតែឃើញមានសក្តានុពលក្នុងការលូតលាស់។ យើងមានវិជ្ជាជីវៈ យើងបង្កើតរចនាសម្ព័ន្ធរបស់យើង ច្រើនឆ្នាំមកហើយ។ ខ្ញុំនៅតែមានសុទិដ្ឋិនិយមចំពោះអាជីវកម្មរបស់ខ្ញុំ ដោយសារយើងរៀបចំផែនការម្តងសម្រាប់រយៈពេលពី ៥ ទៅ ១០ឆ្នាំ។ គ្រប់ពេលដែលយើងធ្វើផែនការ យើងតែងតែទាយទុកពីបញ្ហាប្រឈមពីមជ្ឈដ្ឋានខាងក្រៅ ដូចជា វិបត្តិសេដ្ឋកិច្ចជាដើម។ យើងបានទទួលផលលំបាកច្រើនក្នុងឆ្នាំ២០២០។ ក្នុងឆ្នាំ២០២១ ខ្ញុំមិនគិតថា មានភាពដូចគ្នាទេ។ បើនិយាយពីផ្នែកសេដ្ឋកិច្ច យើងអាចមានសង្ឃឹមខ្លះ ដោយសារវត្តមានវ៉ាក់សាំងដែលទទួលបានពីប្រទេសមួយចំនួន។ សម្រាប់ពីរទៅបីខែខាងមុខទៀត ភាពប្រសើរឡើងវិញនៃសេដ្ឋកិច្ច ត្រូវការពេលវេលាបន្តិច។ បើទោះជាវត្តមានវ៉ាក់សាំងមកយឺតបន្តិចសម្រាប់ប្រទេសខ្លះ យ៉ាងហោចណាស់ប្រទេសជាច្រើន រួមទាំងប្រជាជនរបស់ពួកគេយល់ពីជំងឺនេះ និងដឹងថា ត្រូវទប់ទល់យ៉ាងម៉េច មិនដូចកាលដើមឆ្នាំ២០២០ ទេ។ ពេលនោះយើងមិនដឹងថា ជំងឺនេះជាអ្វី នៅមានមនុស្សមួយចំនួនមិនជឿថា ជំងឺនេះអាចសម្លាប់មនុស្ស។ សរុបមកវិញ ខ្ញុំនៅតែមានសុទិដ្ឋិនិយមចំពោះឆ្នាំ ២០២១ នេះ។

### សំណួរទី៩

*(នាទី ២៨៖៥៧)*

**បុប្ផារ័ត្ន៖** តើគោលនយោបាយអ្វីដែលមានភាពចាំបាច់ជាងគេ ដើម្បីជួយអាជីវកម្មឯកជន ក្នុងការទទួលបានភាពប្រសើរឡើងវិញសម្រាប់គ្រប់គ្នា ចីរភាព និងភាពធន់?

*(នាទី ២៩៖២១)*

**ឧកញ៉ា សុខ ពិសិដ្ឋ៖** សម្រាប់ខ្ញុំ ខ្ញុំគិតថា រាជរដ្ឋាភិបាលមានទិន្នន័យច្រើនជាងយើង។

- ទី១៖ យើងជាប្រទេសកសិកម្ម ហើយខ្ញុំគិតថា រាជរដ្ឋាភិបាលកម្ពុជា គួរតែផ្តោតទៅលើការកែច្នៃកសិផល (agro processing)។
- ទី២៖ រាជរដ្ឋាភិបាលកម្ពុជា គួរតែធានាឲ្យបាននូវបរិយាកាសអាជីវកម្មដែលមានការប្រកួតប្រជែងស្មើភាពគ្នា ដោយសារតែយើងដឹងថា ការប្រកួតប្រជែងអាជីវកម្មខ្លះ មិនមានភាពស្មើគ្នាទេ។ មានការលួចលក់ខុសច្បាប់

ជាច្រើន ជាពិសេសក្នុងវិស័យផលិតផលអេឡិចត្រូនិច។ ក្នុងចំណុចនេះដែរ ប្រសិនបើការផលិត មានទំហំតូច (scaling) ការដែលធ្វើឱ្យតម្លៃថោក ជារឿងមួយដែលពិបាក។ ចំណុចទីពីរគឺ ការបង្កើតតម្លៃបន្ថែមសម្រាប់គាំទ្រសហគ្រាសធុនតូច និងមធ្យម។ រាជរដ្ឋាភិបាល និងវិស័យឯកជន គួរតែពិភាក្សាគ្នា។ រាជរដ្ឋាភិបាល គួរតែយល់ពីគម្រូអាជីវកម្ម (business model) របស់ប្រទេសផងដែរ។ ប្រសិនបើមិនមានការយល់ដឹងពីគម្រូអាជីវកម្មរបស់កម្ពុជា យើងនឹងពិបាកប្រកួតប្រជែងជាមួយប្រទេសជិតខាង។

## សំណួរទី១០

*(នាទី ៣១៖២១)*

**បុប្ផារ័ត្ន៖** តើរាជរដ្ឋាភិបាលកម្ពុជា និងវិស័យឯកជន គួរតែផ្តោតទៅលើវិស័យចម្បងអ្វី ដើម្បីឆ្ពោះទៅកាន់ភាពប្រសើរឡើងវិញ?

*(នាទី ៣១៖២១)*

**ឧកញ៉ា សុខ ពិសិដ្ឋ៖** ខ្ញុំគិតថា មិនមែនត្រឹមតែធនាគារ អេ.អ.ឌី.ប៊ី ដើម្បីកសិករ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម (ARDB) ទេ រាជរដ្ឋាភិបាលមានរចនាហេដ្ឋារចនាសម្ព័ន្ធល្អរួចទៅហើយ សម្រាប់មួយរយៈចុងក្រោយនេះ។ រាជរដ្ឋាភិបាលមានមូលនិធិអភិវឌ្ឍន៍សហគ្រិន (Entrepreneurship Development Fund) ដើម្បីពង្រឹងជំនាញអ្នកដែលមិនមានការងារក្នុងវិបត្តិនេះ ដើម្បីទទួលបានឱកាសការងារ។ រាជរដ្ឋាភិបាលបានបង្កើតធនាគារសម្រាប់សហគ្រាសធុនតូច និងមធ្យម (SMEs bank)។ ដំបូងឡើយ ធនាគារសម្រាប់សហគ្រាសធុនតូច និងមធ្យម ចូលរួមជាមួយនឹងធនាគារពាណិជ្ជ ៥០% ម្នាក់ ដើម្បីជួយដំណើរការសហគ្រាសធុនតូច និងមធ្យម។ ឥឡូវនេះ ធនាគារសម្រាប់សហគ្រាសធុនតូច និងមធ្យម ដំណើរការដោយខ្លួនឯង។ ខ្ញុំបានរៀបរាប់ខាងលើហើយថា វិស័យចម្បង គឺការកែច្នៃកសិផល (agro processing) ពីព្រោះក្នុងការកែច្នៃកសិផល (agro processing) មានផលិតផលជាច្រើន។ ដូច្នេះ រាជរដ្ឋាភិបាល ត្រូវតែដឹងថា ផលិតផលមួយណា គួរជាអាទិភាព។ ការគាំទ្រគួរតែចេញពីគោលនយោបាយផ្ទាល់ទៅលើការផលិត។ គោលនយោបាយគួរតែមានភាពស៊ីសង្វាក់គ្នា។ លើសពីនេះទៀត គួរតែមានការរិតត្បិតការនាំចូលផលិតផលខុសច្បាប់។

## សំណួរទី១១

*(នាទី ៣៤៖១២)*

**បុប្ផារ័ត្ន៖** តើលោកឧកញ៉ាមានមតិយោបល់បន្ថែមទេ?

*(នាទី ៣៤៖២០)*

**ឧកញ៉ា សុខ ពិសិដ្ឋ៖** សម្រាប់ខ្ញុំ ខ្ញុំយល់ថា ជំងឺកូវីដ១៩ ក៏ផ្តល់នូវភាពចំណេញខ្លះដែរ។ វិបត្តិនេះបង្រៀនយើងឱ្យព្យាយាមរកវិធីបន្តជីវិតទៅមុខ។ សម្រាប់មតិយោបល់បន្ថែមរបស់ខ្ញុំទៅកាន់ រាជរដ្ឋាភិបាល និងវិស័យឯកជន យើងត្រូវដឹងពីជំហររបស់យើង។ រដ្ឋាភិបាលគួរតែដឹងពីចំណុចដែលត្រូវពង្រឹង។ វិស័យឯកជន គួរតែជួយគ្នាទៅវិញទៅមក។ ប្រសិនបើមានវិស័យដែលអាចផ្គុំគ្នាបានហើយលូតលាស់បានល្អ យើងគួរតែផ្គុំគ្នា។ ខ្ញុំគិតថា ខណៈពេលនេះជា

ពេលវេលាដ៏ល្អមួយក្នុងការចូលរួមសហការ និងរៀបចំផែនការ សម្រាប់ការរីកលូតលាស់នៃវិស័យសេដ្ឋកិច្ចនាពេលខាងមុខនេះ។ សន្ទុះសេដ្ឋកិច្ចមិនថយចុះរហូតទេ។ វានឹងត្រឡប់មកមានភាពប្រសើរឡើងវិញ។

**មតិបញ្ចប់**

នេះជាចំណុចបញ្ចប់របស់ ផតខាសស៊េរី វិទ្យាស្ថាន CDRI វគ្គទី១របស់យើង។ សូមអរគុណឧកញ៉ា សុខ ពិសិដ្ឋ ដែលបានចូលរួមជាមួយយើងថ្ងៃនេះ។ យើងបានពិភាក្សាច្រើនទៅលើផលប៉ះពាល់ ការឆ្លើយតប ភាពប្រសើរឡើងវិញក្នុងឆ្នាំ២០២១។ នាងខ្ញុំក៏សូមអរគុណប្រិយមិត្តអ្នកស្តាប់ទាំងអស់គ្នាដែរ។